## កិច្ចសម្ភាសន៍ជាមួយនាយកប្រតិបត្តិធនាគារកាណាឌីយ៉ា

**១. ក្នុងនាមជាធនាគារមួយ ក្នុងចំណោមធនាគារដំបូងគេ ដែលបានក្លាយខ្លួនជាគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមរបស់ CGCC, តើកត្តាអ្វីខ្លះដែលជំរុញឱ្យធនាគារកាណាឌីយ៉ាប្រើប្រាស់គម្រោងធានាឥណទានជាមួយនឹងផលិតផលឥណទានរបស់ធនាគារដែលមានស្រាប់?**

កត្តាចំបងមួយដែលជម្រុញឲ្យយើងប្រើប្រាស់គម្រោងធានាឥណទាន ព្រោះយើងជឿជាក់ថា គម្រោងធានាឥណទានរបស់ CGCC អាចជួយដល់ម្ចាស់អាជីវកម្ម ដែលមានសក្តានុពលហើយមានតម្រូវការកម្ចី ប៉ុន្តែមិនមានទ្រព្យធានាកម្ចីគ្រប់គ្រាន់ ឱ្យមានលទ្ធភាពទទួលបានឥណទានច្រើនជាងមុនសម្រាប់បំពេញតម្រូវការហិរញ្ញវត្ថុអាជីវកម្មរបស់ខ្លួនជាពិសេសក្នុងការស្តារ និងពង្រីកអាជីវកម្មក្រោយពីវិបត្តិជម្ងឺកូវីដ-១៩ បានធូរស្រាល ។

**២. បន្ទាប់ពីបានប្រើប្រាស់ គម្រោងធានាឥណទានរបស់ CGCC ជាងមួយឆ្នាំមក តើធនាគារកាណាឌីយ៉ាយល់ថាគម្រោងធានាឥណទានបានជួយគាំទ្រដល់ធនាគារ និងអតិថិជនរបស់ធនាគារកាណាឌីយ៉ាយ៉ាងដូចម្តេចខ្លះ?**

យើងបានផ្តល់ឥណទាន ក្រោមគម្រោងធានាឥណទានរបស់ CGCC ជូនអតិថិជនច្រើនជាង ២០០នាក់ជាមួយទំហំឥណទានសរុបជិត ២០លានដុល្លារអាមេរិក ក្នុងរយៈពេលជាងមួយឆ្នាំនេះ។ អតិថិជនបានកំពុងប្រើប្រាស់ឥណទានដែលមានការធានាពី CGCC ទាំងនេះ ដើម្បីពង្រីកអាជីវកម្មរបស់គាត់ក្នុងវិស័យផ្សេងៗ ដែលបានបង្កើតការងារជូនប្រជាជន និង រួមចំណែកយ៉ាងសំខាន់ក្នុងការស្តារសេដ្ឋកិច្ចប្រទេសឡើងវិញ។



លោក Raymond Sia
នាយកប្រតិបត្តិធនាគារកាណាឌីយ៉ា

**៣. តើធនាគារកាណាឌីយ៉ា បានរៀបចំលក្ខខណ្ឌផលិតផលឥណទានរបស់ខ្លួនយ៉ាងដូចម្តេចខ្លះដើម្បីដាក់រួមបញ្ចូលជាមួយការធានាឥណទានឱ្យមានប្រសិទ្ធភាព?**

យើងមានកម្មវិធីផ្តល់ឥណទានដែលមានការធានាពី CGCC សម្រាប់អតិថិជន ដែលមានអាជីវកម្មសក្តានុពលមានប្រវត្តិសងឥណទានល្អ និងមានគម្រោងប្រើប្រាស់ឥណទានច្បាស់លាស់។ ឥណទាននេះអាចផ្តល់ជូនបានទាំងអតិថិជនដែលកំពុងប្រើប្រាស់សេវាកម្មជាមួយធនាគារកាណាឌីយ៉ា និងអតិថិជនថ្មី។




**៤. ថ្មីៗនេះធនាគារកាណាឌីយ៉ា និងសាជីវកម្មធានាឥណទានកម្ពុជាបានដាក់ឱ្យប្រើប្រាស់នូវផលិតផល និង គម្រោងដើម្បីគាំទ្រដល់សហគ្រិនស្ត្រី រួមមានឥណទានសហគ្រិនស្ត្រីវៃឆ្លាត និងគម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រី។ តើធនាគារយល់ឃើញថាផលិតផល និងគម្រោងទាំង២នេះ មានអត្ថប្រយោជន៍យ៉ាងណាខ្លះ ក្នុងការគាំទ្រដល់សហគ្រិនស្ត្រីឱ្យទទួលបានកម្ចី ទោះបីខ្វះទ្រព្យបញ្ចាំក៏ដូចជាដើម្បីបង្កើនបរិយាបន្នហិរញ្ញវត្ថុ?**

ឥណទានសហគ្រិនស្ត្រី និងគម្រោងធានាឥណទានសម្រាប់សហគ្រិន កំពុងបានរួមចំណែកយ៉ាងសំខាន់ក្នុងការជួយឱ្យសហគ្រិនស្ត្រីទទួលបានឥណទានសមស្របតាមតម្រូវការអាជីវកម្មរបស់ពួកគាត់ ជៀសវាងការស្វែងរកកម្ចីដែលមានថ្លៃដើមខ្ពស់ និងប្រកបដោយហានិភ័យ។ តាមរយៈគម្រោងទាំងពីរខាងលើ សហគ្រិនស្ត្រីមិនត្រឹមតែមានលទ្ធភាពទទួលបានឥណទានតាមតម្រូវការរបស់ខ្លួន និងងាយស្រួលជាងមុនទេ ប៉ុន្តែបានកាត់បន្ថយថ្លៃដើមផ្នែកហិរញ្ញវត្ថុយ៉ាងច្រើនជាពិសេសក្នុងឆ្នាំទី១ ដែលរួមមានអត្រាការប្រាក់ទាបនិងកម្រៃសេវាឥណទានដែលត្រូវបានកាត់បន្ថយផងដែរ។ លើសពីនេះទៅទៀតសហគ្រិនស្ត្រី នឹងទទួលបានអត្ថប្រយោជន៍ផ្សេងៗទៀតជាច្រើន តាមរយៈកញ្ចប់ឥណទានស្ត្រីវៃឆ្លាតពីធនាគារកាណាឌីយ៉ា។

**៥. ធនាគារកាណាឌីយ៉ាគឺជាធនាគារ ដែលបានបញ្ចេញឥណទានដែលមានការធានាក្រោមគម្រោងធានាឥណទានរបស់ CGCC បានច្រើនជាងគេក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម របស់ CGCC ដទៃទៀត។ តើធនាគារកាណាឌីយ៉ាមានយុទ្ធសាស្ត្រយ៉ាងណាក្នុងការបន្តពង្រីកការប្រើប្រាស់គម្រោងធានាឥណទាន ជាពិសេសទៅកាន់តំបន់ជនបទ?**

យើងបន្តការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយទៅដល់អតិថិជនគោលដៅរបស់យើង ជាពិសេសអតិថិជនដែលមានអាជីវកម្មសក្តានុពលតែពុំមានទ្រព្យធានាគ្រប់គ្រាន់។ យើងក៏នឹងបន្តភ្ជាប់គម្រោងធានាឥណទាន ជាមួយនឹងគម្រោងផលិតផលថ្មីៗទៀតរបស់យើង ដើម្បីផ្តល់ជម្រើសកាន់តែសម្បូរបែបជូនដល់អតិថិជន ។

**៦. ដោយសារតែប្រធានបទ ការធានាឥណទានជាប្រធានបទមួយថ្មីនៅកម្ពុជា តើធនាគារកាណាឌីយ៉ា និងសាជីវកម្មធានាឥណទានកម្ពុជា គួរតែធ្វើអ្វីបន្ថែមដើម្បីលើកកម្ពស់ការយល់ដឹងពីការធានាឥណទានទៅកាន់អ្នកស្នើសុំកម្ចី?**

ដើម្បីលើកកម្ពស់ការយល់ដឹង អំពីការធានាឥណទានយើងគួរបន្តការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយជាពិសេសម្ចាស់អាជីវកម្មនានា តាមរយៈបណ្តាញសង្គម សិក្ខាសាលា សមាគមអាជីវករ ។ល។